ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

## តាងនាមប្រជារាស្ត្រខ្មែរ

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៧៤៩/២០-០៨-១៣ បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ក្រ ចុះថ្ងៃទី ០៨-០២-៩៣

**សាលដីកា** បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍នាថ្ងៃទី ០៦-០២-១៤

លេខ ១២ ក្រ"ឃ"ចុះ ដែលមានសមាសភាពដូចតទៅៈ

ថ្ងៃទី ១២-០២-២០១៤

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

បានបើកសវនាការជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌដែលមានលេខ ៧៤៩ ចុះថ្ងៃទី ២០-០៨-១៣ រវាង ៖

-ជនជាប់ចោទឈ្មោះ

១-[redacted] **ស៊ិរិទ្ធី** ហៅ **រិត** ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ[redacted] ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០២នាក់ ទោសពីមុនគ្មាន (ឃុំខ្លួន)។ (ប្តឹងឧទ្ធរណ៍)

២-[redacted] **តូនី** ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មុខរបរ គូកជេរឡាន ទីកន្លែងកំណើតផ្សារមាន់អាំង ខណ្ឌទួលគោក រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នផ្ទះលេខ [redacted] ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០១នាក់ ទោសពីមុនគ្មាន (ឃុំខ្លួន)។ (ប្តឹងឧទ្ធរណ៍)

**ត្រូវជាប់ចោទពីបទ** ៖ ហឹង្សាដោយចេតនាមានស្ថានទម្ងន់ទោស





Scanned with CamScanner

ប្រព្រឹត្តនៅភូមិជប់ព្រីង ឃុំថ្មី ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង កាលពីថ្ងៃទី ០៨-៤-២០១២ តាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មុខរបរ គូកដេរឡាន ទីកន្លែងកំណើតផ្សារមាន់អាំង ខណ្ឌទួលគោក រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នផ្ទះលេខ [redacted]។

-ជនរងគ្រោះឈ្មោះ [redacted] សុវណ្ណៈ ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted]។

## ឯរឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី ០៨-០៤-២០១២ វេលាម៉ោង ៧.៤៥នាទីយប់ នៅភូមិជប់ព្រីង ឃុំថ្មី ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង មានកើតអំពើហិង្សាដោយចេតនាដោយប្រើអាវុធទៅលើគូទំនាស់ បង្កដោយឈ្មោះ [redacted] គូនី វាយឈ្មោះ [redacted] សុវណ្ណៈ មួយដំបងពីក្រោយដួលសន្លប់នៅច្រកចូលផ្ទះឈ្មោះ [redacted] សារ៉ាន់ ដែលត្រូវជាឪពុកក្មេករបស់ឈ្មោះ [redacted] សុវណ្ណៈ។ បន្ទាប់ពីដឹងថា ឈ្មោះ [redacted] គូនី វាយឈ្មោះ [redacted] សុវណ្ណៈ ឈ្មោះ [redacted] ស៊ីរិទ្ធិ ត្រូវជាប្អូនថ្លៃ ព្រមទាំងបក្ខពួកបាននាំគ្នាទៅរករឿងឈ្មោះ [redacted] គូនី ហើយព្រួតគ្នាវាយលើឈ្មោះ [redacted] គូនី រហូតដល់សន្លប់វិញដែរ។ ក្នុងរឿងនេះឈ្មោះ [redacted] សុវណ្ណៈ ពុំបានប្តឹងទាមទារសំណងអ្វីទេ តែឈ្មោះ [redacted] គូនី ដែលជាជនជាប់ចោទ និងជាជនរងគ្រោះបានប្តឹងទាមទារជម្ងឺចិត្តចំនួន ៥០០០$។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ០៩"ឆ" ចុះថ្ងៃទី ២០-០៦-២០១៣ របស់សាលាដំបូងខេត្តស្វាយរៀង ដែលមានខ្លឹមសារសម្រេចដូចខាងក្រោម៖

១-ផ្តន្ទាទោសលើឈ្មោះ [redacted] ស៊ីរិទ្ធិ ហៅ រិត ភេទប្រុស អាយុ៣០ឆ្នាំ និងឈ្មោះ [redacted] គូនី ភេទប្រុស អាយុ៣២ឆ្នាំ ដាក់ពន្ធនាគារកំណត់០២"ពីរឆ្នាំ" និងបង្គាប់ឱ្យចាប់ខ្លួន និងឃុំខ្លួនលើឈ្មោះ [redacted] ស៊ីរិទ្ធិ ហៅ រិត និងឈ្មោះ [redacted] គូនី ដែលមានសាវតាជាតិដូចខាងលើពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិជប់ព្រីង ឃុំថ្មី ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង កាលពីថ្ងៃទី ០៨-០៤-២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យឈ្មោះ [redacted] ស៊ីរិទ្ធិ ហៅ រិត សងសំណងថ្លៃថ្នាំព្យាបាល និងជម្ងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចំនួន ៦ ០០០ ០០០៛,០០"ប្រាំមួយលានរៀល"។ ការទាមទារលើសពីនេះសម្រេចច្រានចោល។

៣-វត្ថុតាង ពូថៅមួយដងធ្វើពីឈើមានប្រវែង ៤៨សង្ទីម៉ែត្រ និងមានផ្លែប្រវែង ១៣,៥០ សង្ទីម៉ែត្រ "ដងបែកខាងគល់" មែកដើមគមួយកំណាត់មានទំហំ ០៥សង្ទីម៉ែត្រ មានប្រវែង១,៣៧ ម៉ែត្រ ស្រួចផ្នែកគល់ និងខាងចុងមានចំពាមពីរ និងមែកប្រេងខ្យល់មួយកំណាត់ទំហំ ០៥សង្ទីម៉ែត្រ ប្រវែង ៥០សង្ទីម៉ែត្រ មានស្នាមកាត់ត្រឹមនៅផ្នែកគល់ និងមានជាប់ចំពាមផ្នែកខាងចុងស្រួច សម្រេចរឹបអូសបំផ្លាញចោល។

៤-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២០-០៦-២០១៣ ចំពោះ

មុខជនជាប់ចោទ [redacted] ស៊ីរិទ្ធី ហៅ រិត និងឈ្មោះ [redacted] តូនី។

បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៤-០៧-២០១៣ របស់ឈ្មោះ [redacted] ~~ស៊ីរិទ្ធី~~ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ០៩"ធ" ចុះថ្ងៃទី ២០-០៦-២០១៣ របស់សាលាដំបូងខេត្តស្វាយរៀង ត្រង់ចំណុចទី១ និងទី២ នៃសាលក្រម។

-បានឃើញឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១០-០៧-២០១៣ របស់ឈ្មោះ [redacted] **តូនី** សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ០៩"ធ" ចុះថ្ងៃទី ២០-០៦-២០១៣ របស់សាលាដំបូងខេត្តស្វាយរៀង ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញរបាយការណ៍របស់ចៅក្រមសាលាឧទ្ធរណ៍ចុះថ្ងៃទី ២៤-១២-២០១៣។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការចុះថ្ងៃទី ១៥-០១-២០១៤ ។

**<u>នាពេលសវនាការសាលាឧទ្ធរណ៍</u>**

ចៅក្រមអានរបាយការណ៍រឿង

-ឈ្មោះ [redacted] ស៊ីរិទ្ធី បានឆ្លើយថា ខ្លួនប្តឹងឧទ្ធរណ៍មកនេះដោយសារខ្លួនមិនបានប្រព្រឹត្តទេ ដោយរឿងហេតុដំបូងខ្លួនមកពីកិនស្រូវគេ ឃើញឈ្មោះ [redacted] តូនី មកផឹកផ្ទះខ្លួនជាមួយបងថ្លៃខ្លួនឈ្មោះ [redacted] សុវណ្ណៈ ដោយឈ្មោះ [redacted] តូនី បានហៅខ្លួនហូបជាមួយគាត់មួយពែងទៀតផង បន្តិចមកក៏មានទំនាស់គ្នាជាមួយបងថ្លៃខ្លួនពីរឿងឈ្មោះ [redacted] តូនី និយាយភាសាវៀតណាមបងថ្លៃខ្លួនមិនចូលចិត្តហើយបានបែកគ្នាទៅ តែក្រោយមកថាមានរឿងវាយគ្នានោះខ្លួនពុំបានដឹងទេ។ រីឯអ្នកណាវាយឈ្មោះ [redacted] សុវណ្ណៈ ខ្លួនមិនបានដឹងទេ ចំណែកឈ្មោះ [redacted] អូន ខ្លួនស្គាល់នៅផ្ទះទល់មុខ។ ខ្លួនមិនបានវាយទៅលើឈ្មោះ [redacted] តូនី ទេ ដោយពេលនោះខ្លួននៅរោងបុណ្យជាមួយប្អូនថ្លៃរបស់ឈ្មោះ [redacted] តូនី និងមានសាក្សីផ្សេងទៀតឈ្មោះ [redacted] ភ័ក្ត្រ , [redacted] វឿន , [redacted] សាខន។ ខ្លួនមិនធ្លាប់មានទំនាស់ជាមួយឈ្មោះ [redacted] តូនី ទេ។ ខ្លួនសំណូមពរសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះជួយរកយុត្តិធម៌ដល់រូបខ្លួន។

-ឈ្មោះ [redacted] តូនី បានឆ្លើយថា នៅថ្ងៃកើតហេតុខ្លួននៅផ្ទះគេបានមកដល់មុខផ្ទះខ្លួន ហើយជេរម្តាយខ្លួន បន្ទាប់មានម្នាក់ទៀតមកពីក្រោយធាក់ទ្វាចូលមកវាយខ្លួនឈ្មោះ ស៊ីរិទ្ធី ខ្លួនមិនបានវាយតបទេ គេមានគ្នាច្រើនជាង១០នាក់ វាយខ្លួនបណ្តាលឱ្យបាក់ដៃ។ ខ្លួនមិនស្គាល់ឈ្មោះ [redacted]-សុវណ្ណៈ ទេ ស្គាល់តែមុខពេលចេញចូលផ្ទះរបងជាប់គ្នា។ ខ្លួនបាននិយាយភាសាវៀតណាមបកប្រែឱ្យគេមករកជួលដី ហើយខ្លួនមិនបានវាយឈ្មោះ [redacted] សុវណ្ណៈ ទេ , គេបានយកដំបងមកវាយខ្លួន គឺឈ្មោះ [redacted] ស៊ីរិទ្ធី និងបក្ខពួក តែខ្លួនគ្មានភស្តុតាងមកបញ្ជាក់ទេ គឺស្គាល់សំឡេងច្បាស់។ ខ្លួនសំណូមពរសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះដោះលែងខ្លួនឱ្យមានសេរីភាព។

**<u>តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា</u>**

-អង្គហេតុនៃអំពើហិង្សាដោយចេតនានេះពិតជាកើតមានមែនដែលបង្កឡើងដោយជនល្មើសទាំងពីរនាក់នេះ និងអង្គហេតុក៏មិនមានប្រែប្រួលដែរពិតមែនតែជនជាប់ចោទម្នាក់ឈ្មោះ



Scanned with CamScanner

[redacted] ស៊ីរិទ្ធី ហ៊ឹងបានបដិសេធនាពេលសវនាការនេះថា ខ្លួនគេមិនបានប្រព្រឹត្តទៅលើឈ្មោះ [redacted] តូនី ក៏ដោយ តែឈ្មោះ [redacted] តូនី មានរបួសស្នាមដែលបង្កឡើងដោយឈ្មោះ [redacted] ស៊ីរិទ្ធី នេះដែរ ដូច្នេះអង្គហេតុ និងបទល្មើសដែលមាននៅក្នុងអង្គហេតុនេះវាគាំទ្រទៅដល់សេចក្ដីសម្រេចរបស់សាលាដំបូងខេត្តស្វាយរៀង ដែលបានផ្ដន្ទាទោសទៅលើជនជាប់ចោទទាំងពីរនេះ ក៏ប៉ុន្តែតំណាងមហាអយ្យការពិនិត្យឃើញថា ព្យសនកម្មដែលឈ្មោះ [redacted] ស៊ីរិទ្ធី បានប្រព្រឹត្តមកលើឈ្មោះ [redacted] តូនី នេះមានក្ខណៈធ្ងន់ធ្ងរ។ ពិតមែនតែឈ្មោះ [redacted] តូនី បានបង្កហេតុមុនដំបូងបានវាយទៅលើឈ្មោះ [redacted] សុវណ្ណៈ ដើមដំបូងក៏ដោយ តែឈ្មោះ [redacted] សុវណ្ណៈ មិនបានប្ដឹងឈ្មោះ [redacted] តូនី ទេ ប៉ុន្តែឈ្មោះ [redacted] ស៊ីរិទ្ធី មានកំហឹងពុះពោរបានបង្កហិង្សាយ៉ាងឃោរឃៅវាយទៅលើឈ្មោះ [redacted] តូនី ជាជនជាប់ចោទផង និងជាជនរងគ្រោះផងរហូតដល់បាក់ដៃ។ ដូច្នេះសេចក្ដីសម្រេចរបស់សាលាដំបូងខេត្តស្វាយរៀង អាចគាំទ្រទៅនឹងអង្គហេតុដែលមានបទល្មើសនៅក្នុងសំណុំរឿងនេះហើយ ក៏ប៉ុន្តែដោយពិនិត្យទៅលើព្យសនកម្ម និងការរងគ្រោះរបស់ឈ្មោះ [redacted] តូនី ដូចបង្ហាញនៅក្នុងពេលសវនាការនេះ សុំឱ្យលោកពិចារណាទៅលើសេចក្ដីសម្រេចដែលបានផ្ដន្ទាទោសទៅលើឈ្មោះ [redacted] តូនី លើការដាក់ទណ្ឌកម្ម ដែលជាជនជាប់ចោទ,ជាជនរងគ្រោះនិងជាដើមបណ្ដឹងរងនូវព្យសនកម្មធ្ងន់ធ្ងរ បែរជាទទួលស្មើគ្នាជាមួយអ្នកបង្កម្នាក់ទៀតគ្មានរបួសស្នាមអ្វី សុំឱ្យក្រុមប្រឹក្សាពិចារណាលើទណ្ឌកម្មរបស់ឈ្មោះ [redacted] តូនី។

## សភាព្រហ្មទណ្ឌយល់ឃើញថា

១-បណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ០៤-០៧-២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីរិទ្ធី និងបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ១០-០៧-២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] តូនី ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ០៩"ឆ" ចុះថ្ងៃទី ២០-០៦-២០១៣ របស់សាលាដំបូងខេត្តស្វាយរៀង ធ្វើឡើងក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សភាព្រហ្មទណ្ឌអាចទទួលជំនុំជម្រះបាន។

២-កាលពីថ្ងៃទី ០៨-០៤-២០១២ វេលាម៉ោង ៧.៥៥នាទីយប់ នៅភូមិជប់ព្រីង ឃុំថ្មី ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង មានករណីអំពើហិង្សាដោយអាវុធមួយកើតឡើងបង្កដោយឈ្មោះ [redacted] តូនី វាយទៅលើឈ្មោះ [redacted] សុវណ្ណៈ។ បន្ទាប់មកក្រោយដឹងថា ឈ្មោះ [redacted] តូនី វាយឈ្មោះ [redacted] សុវណ្ណៈ , ឈ្មោះ [redacted] ស៊ីរិទ្ធី និឈ្មោះ [redacted] ធារី និងបក្ខពួកបាននាំគ្នាទៅរករឿងឈ្មោះ [redacted] តូនី ដល់ផ្ទះ ហើយព្រួតគ្នាវាយឈ្មោះ [redacted] តូនី រហូតដល់សន្លប់។

៣-ជនជាប់ចោទឈ្មោះ [redacted] តូនី និងឈ្មោះ [redacted] ស៊ីរិទ្ធី បានឆ្លើយបដិសេធរៀងៗ ខ្លួនថា ពុំបានវាយគ្នាទៅវិញទៅមកឡើយ។

៤-តាមចម្លើយសាក្សីឈ្មោះ [redacted] សុជា បានបញ្ជាក់ថា កាលពីយប់ថ្ងៃកើតហេតុ ខ្លួនឃើញឈ្មោះ [redacted] ធារី និងឈ្មោះ [redacted] ស៊ីរិទ្ធី ព្រួតគ្នាវាយទៅលើឈ្មោះ [redacted] តូនី ជាប្ដីរបស់ខ្លួនរហូតដល់បាក់ដៃ។

៥-រឿងក្ដីនេះសាលាដំបូងបានធ្វើការស៊ើបសួរនិងសើកសំអាងហេតុមកបញ្ជាក់មានលក្ខណៈត្រឹមត្រូវហើយ ដូច្នេះសភាព្រហ្មទណ្ឌ ឯកភាពតាមសំអាងហេតុនេះទាំងស្រុង។

៦-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] តូនី និងឈ្មោះ [redacted] ស៊ីរិទ្ធី ពីបទ





Scanned with CamScanner

ហើយក្រោយ ដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិជប់ព្រីង ឃុំថ្មី ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង កាលពីថ្ងៃទី ០៨-០៩-២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។

៧-ជនជាប់ចោទទាំងពីររូបទើបប្រព្រឹត្តបទល្មើសជាលើកដំបូង មានកំរិតវប្បធម៌ទាបខ្វះការពិចារណាដិតដល់។ ម៉្យាងទៀតជនជាប់ចោទឈ្មោះ [redacted] តូនី ក៏ជាជនរងគ្រោះផងដែរ ដូច្នេះគប្បីក្រុមប្រឹក្សាពិចារណាអំពីការបន្ធូបន្ថយទោសដល់ជនជាប់ចោទទាំងពីររូបនេះតាមច្បាប់។

៨-សាលក្រមព្រហ្មទណ្ឌលេខ ០៩"ឆ" ចុះថ្ងៃទី ២០-០៦-២០១៣ របស់សាលាដំបូងខេត្តស្វាយរៀង សម្រេចសេចក្តីមានលក្ខណៈត្រឹមត្រូវហើយ គួរតម្កល់ទុកជាបានការ លើកលែងតែចំណុចទី១ គួរបន្ធូបន្ថយទណ្ឌកម្មលើជនជាប់ចោទទាំងពីររូបតាមច្បាប់។

ហេតុដូច្នេះ

## **ទនិច្ឆ័យសេចក្ត**

១-ទទួលបណ្តឹងចុះថ្ងៃទី ០៩-០៧-២០១៣ របស់ជនជាប់ឈ្មោះ [redacted] ស៊ីរិទ្ធី និងបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១០-០៧-២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] តូនី ទុកជាត្រឹមត្រូវតាមច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៩"ឆ" ចុះថ្ងៃទី ២០-០៦-២០១៣ របស់សាលាដំបូងខេត្តស្វាយរៀង ទុកជាបានការលើកលែងតែចំណុចទី១ ស្តីពីទណ្ឌកម្មពន្ធនាគារត្រូវបន្ថយមកត្រឹមចំនួន ០១ឆ្នាំ វិញ។

-ចំណុចផ្សេងពីនេះ រក្សាទុកជាបានការដដែល។

៣-សាលដីកានេះប្រកាសជាសាធារណៈ នៅថ្ងៃទី ១២-០២-២០១៤ ចំពោះមុខជនជាប់ចោទ និងជាដើមបណ្តឹងរដ្ឋប្បវេណី។

-បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

សាលាឧទ្ធរណ៍ថ្ងៃទី ២៦ ខែ ០៣ ឆ្នាំ ២០១៤

| បានឃើញ | ក្រឡាបញ្ជី |
|---|---|
| **ប្រធានសាលាឧទ្ធរណ៍** | |
| [redacted] | [redacted] |



Scanned with CamScanner